# កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម

## មេរៀនជីវិត: កំដៅថ្ងៃធ្វើអោយអ្នកអស់កម្លាំង

## មេរៀនព្រលឹងវិញ្ញាណ: តើបន្ទុករបស់ខ្ញុំមានថ្ងៃបញ្ចប់ទេ?

### សេចក្តីផ្តើម

**ក:** យី ដូចជាក្តៅស្អុះស្អាប់ដល់ហើយហ្ន៎!!!! បកផ្លិត..... បងខេនឯងមើលទៅដូចជាមិនស្អុះស្អាប់អីសោះចឹង!!

**ខ:** យី ម៉េចដឹង ថាឯងមិនស្អុះ។ ស្អុះសឹងថប់ដង្ហើមហើយហ្នឹង! មើលទៅអាកាសធាតុស្រុកយើងឥឡូវ ដូចជាប្រែប្រួលខុសពីធម្មតាណាស់

**ណារី:** ចាស បងប្អូនស្ត្រី តើបងប្អូនដូចជាបងប្អូនយើងពីរនាក់ខាងលើនេះអត់? ចាស ទោះបីជាពេលនេះអ្នកមិនស្អុះ តែខ្ញុំដឹងថាអ្នកក៏ធ្លាប់មានអារម្មណ៍បែបនេះដែរ មែនទេ? ដូច្នេះកម្មវិធីស្ត្រីក្នុងក្តីសង្ឃឹមយើងនៅសប្តាហ៍នេះ យើងនឹងនិយាយពីកំដៅថ្ងៃដែលមកប៉ះខ្លួនយើងរាល់ថ្ងៃ តើវាជះឥទ្ធិពលយ៉ាងណាខ្លះដល់រាងកាយរបស់យើងនោះ សូមបងប្អូនតាមដានជាមួយកម្មវិធីយើងដូចតទៅ

……………………………………………ភ្លេង ……………………………………………………………

## មេរៀនជីវិត: កំដៅថ្ងៃធ្វើអោយអ្នកអស់កម្លាំង

**បូផា:** ចាស កម្មវិធីស្រ្តីក្នុងក្តីសង្ឃឹម សូមស្វាគមន៍ និងសូមជំរាបសួរដល់ប្រិយ៍មិត្តអ្នក ស្តាប់ទាំងអស់។ នៅសប្តាហ៍នេះ នៅតែបានជួបជាមួយខ្ញុំ បូផា

**ណារី:** ចាស ហើយនាងខ្ញុំ ណារី។ តើបងប្អូនសុខសប្បាយអត់? ចាស ហើយយើងខ្ញុំសង្ឃឹមថា បងប្អូនរបស់យើងសុខសប្បាយទាំងអស់គ្នា មែនទេបង?

**បូផា:** ចាស ពិតមែនហើយអូន។ បងប្អូនស្រ្តី យើងនឹងរៀនជាមួយគ្នាបន្តិចពីអាកាសធាតុនៅក្នុងប្រទេសរបស់យើង។ ចាស ណារី យើងឃើញថា នៅប្រទេសយើងមានរដូវពីរធំៗ គឺរដូវប្រាំង និងរដូវវស្សា។ រដូវវស្សាចាប់ពីចុងខែមេសា រហូតដល់ខែសីហា ដែលមានភ្លៀងធ្លាក់ច្រើននៅចន្លោះខែឧសភា និងមិថុនា បន្តរហូតដល់ខែតុលា។ ចំណែករដូវប្រាំងវិញ ចាប់ពីខែវិច្ឆិកា រហូតទៅដល់ខែមេសា ដែលមានសីតុណ្ហភាពពី ២៧អង្សា រហូតដល់៤០អង្សា ពិសេសនៅខែមេសា កំដៅអាចឡើងដល់៤០អង្សាឯណោះ គឺក្តៅមែនទែន។

**ណារី:** ចាស ពិតមែនហើយបង ហើយនៅពេលដែលបងប្អូនយើងធ្វើការនៅក្រោមកំដៅថ្ងៃខ្លាំងពេកចឹង ពិតជាធ្វើអោយពួកគាត់ងាយអស់កម្លាំង ហើយខ្សោះខ្លួនថែមទៀតផង។

**បូផា:** ចាស ពិតមែនហើយអូន ព្រោះថាបងក៏ធ្លាប់ជួបការនេះដែរ គឺនៅពេលដែលបងចុះទៅបង្រៀនតាមភូមិចឹងដែរ។ ចាស ហើយបើយើងមើលទៅលើអ្នកដែលធ្វើស្រែចំការវិញ ពួកគាត់ព្យាយាមស្លៀកពាក់ខោអាវជិតដៃ ជិតជើង ពិសេសទៅទៀតមានមួកទៀតផង ហើយបើមិនការពារចឹងទេ គឺទ្រាំមិនបានក្រោមកំដៅថ្ងៃទេ។

**ណាវី:** ចាស បង ពេលបងនិយាយចឹង ខ្ញុំចាំបានពេលថ្ងៃមួយ ដែលខ្ញុំឈរក្រោមកំដៅថ្ងៃ គឺធ្វើអោយខ្ញុំឈឺក្បាលខ្ទោកៗតែម្តង ជាពិសេសពេលដែលឈរនៅថ្ងៃត្រង់ អូយ...ពិតជាក្តៅមែនទែន។ ហើយមិនតែប៉ុណ្ណោះទេ ស្បែកខ្ញុំក៏ចាប់ផ្តើមស្ងួត គ្មានសំណើម មើលទៅដូចជាផ្កាមិនបានស្រោចទឹកអញ្ចឹងដែរ។

**បូផា:** អូ អូននិយាយចឹង បងនឹកឃើញពីការមួយដែរ ពេលបងឈឺក្បាល ហើយរាងដូចជាខ្សោះៗក្នុងខ្លួន បងក៏បានទៅជួបពេទ្យ ពេលនោះលោកគ្រូពេទ្យមានប្រសាសន៍ថា អោយបងញ៉ាំទឹកអោយបានច្រើន ជាពិសេសនៅខែក្តៅ ព្រោះរាងកាយយើងត្រូវការទឹកមែនទែន ហើយបើមិនចឹងទេ ស្បែកយើងពិតជាស្រពោន ដូចជាផ្កាដែលណាវី និយាយចឹង។( សើច)

**ណាវី:** ជាងនេះទៅទៀត បងប្អូនស្រ្តី នៅពេលដែលយើងដើរហាលថ្ងៃ ឬធ្វើការនៅក្រោមកំដៅថ្ងៃច្រើនពេក នោះវាអាចធ្វើអោយកំដៅក្នុងខ្លួនយើងឡើងខ្ពស់ជាងធម្មតា ហើយបើគ្មានវិធីកាត់បន្ថយទេ នោះវានឹងធ្វើអោយយើងសន្លប់បាត់ស្មារតី។ ចាស បងបូផា យើងឃើញថាយើងម្នាក់ៗបែកញើសជោគ នៅពេលដែលក្តៅខ្លាំង ដោយសារតែរាងកាយយើងមានក្រពេញ

ញើស ដែលគ្រប់ដណ្តប់លើស្បែករបស់យើង ហើយវាបញ្ចេញញើសតិចៗមក ដើម្បីកាត់បន្ថយកំដៅនៅលើស្បែកយើង។ ការនេះមើលទៅគួរអោយអស្ចារ្យមែនទែន តើបងប្អូនគិតដូចជាខ្ញុំអត់?

**បូផា:** ចាស ហើយយើងមើលឃើញថា សីតុណ្ហភាពនៅក្នុងខ្លួនយើងមានការផ្លាស់ប្តូរ មែនអត់អូន គឺនៅពេលយើងក្តៅ យើងចាប់ផ្តើមបែកញើស ហើយយើងបែកញើសកាន់តែច្រើននៅពេលដែលយើងក្តៅខ្លាំង។ បើសិនជាយើងមិនធ្វើអ្វីអោយកំដៅថយចុះទេ យើងពិតជាចង់ក្អួត ហើយមានអារម្មណ៍ល្វើយៗ អស់កម្លាំង ឈឺក្បាល និងខ្សោះនៅក្នុងខ្លួនថែមទៀតផង ហើយជាពិសេសសំពាធឈាមរបស់យើងក៏ឡើងដែរ។ ម្យ៉ាងវិញទៀត ខួរក្បាលអាចប៉ះពាល់ខ្លាំងរហូតដល់ឈឺក្បាលខ្លាកៗ ដោយសារតែវាជាសរីរាង្គមួយដែលងាយទទួលរងគ្រោះថ្នាក់ជាងគេ។

**ណារី:** ចាស បងប្អូនស្រ្តី បើសិនជាមនុស្សម្នាក់ទទួលសំពាធកំដៅខ្លាំងពេក ដែលបណ្តាលអោយអ្នកល្វើយ ហើយឈឺក្បាល ឬមួយរហូតដល់សន្លប់ អ្នកគប្បីទៅអង្គុយទៅកន្លែងម្លប់ យកទឹកកកស្អំលើក្បាល កញ្ចឹងក ឬ គ្រង់ក្លៀក ឬ បកខ្លិតធ្វើអោយត្រជាក់ នោះវាជួយអោយរាងកាយរបស់អ្នកថយកំដៅជាងមុនផងដែរ។

**បូផា:** ចាស បងប្អូនស្រ្តី ដូចជាអ្វីដែលណារីបានប្រាប់ចឹង ហើយបើកាលណាយើងបណ្តោយខ្លួនយើងអោយទទួលកំដៅច្រើនពេក រហូតហូតជាតិទឹកពីក្នុងខ្លួនយើងអស់នោះ វាបណ្តាល

អោយយើងជួបគ្រោះថ្នាក់ដែរ។ ដូច្នេះ ដើម្បីចៀសវាងកុំអោយកាលនេះកើតឡើង សូមមេត្តាទទួលទានទឹកអោយបានច្រើន ជាពិសេសនៅពេលណាដែលអ្នកធ្វើការក្រោមកំដៅថ្ងៃច្រើន។ ម្យ៉ាងវិញទៀត សូមពាក់មួក ព្រោះដូចជាអ្វីដែលយើងបានជំរាបជូនខាងលើថា ខួរក្បាលយើងងាយទទួលរងគ្រោះថ្នាក់ជាងគេ ហើយការដែលពាក់អាវដៃវែងនោះ កាន់តែប្រសើរទៅទៀត។

**ណារី:** ចាស បងប្អូនស្រ្តី ជាមួយគ្នានេះផងដែរ បើសិនជាបងប្អូនស្រ្តី ដែលធ្វើការនៅជិតកំដៅច្រើន ដូចជាអ្នកដុតនំ ចៀននំ អ្នកធ្វើថ្នល់កៅស៊ូនោះ ពេលអ្នកទទួលកំដៅច្រើនគួរសមហើយគួរដកខ្លួនសំរាកបន្តិច ដើម្បីកុំអោយកំដៅក្នុងខ្លួនអ្នកកើតទៀត រួចសឹមបន្តការងារនោះទៀត ពិសេសសូមទទួលទានទឹកអោយបានច្រើន។

**បូផា:** ចាស បងប្អូនស្រ្តី ពីកម្មវិធីសង្ឃឹមថា បងប្អូនមិនភ្លេចក្នុងការទទួលទានទឹក ព្រោះបើតាមបងដឹង ណារី ក្នុងមួយថ្ងៃយើងម្នាក់ៗ ត្រូវទទួលទានទឹក ពី ២លីត្រ ទៅ៣លីត្រ ដូច្នេះសូមបងប្អូនពិសារទឹកអោយបានច្រើន ដើម្បីសុខភាពរបស់បងប្អូនដែរ។ ចាស ហើយជាបន្តទៅទៀតនេះ សូមបងប្អូនបានសំរាកជាមួយបទចំរៀងមួយបទសិន មុននឹងយើងចូលដល់មេរៀនខាងឯព្រលឹងវិញ្ញាណ។ ចាស សូមអញ្ជើញ

…………………………………………………….ចំរៀង ………………………………………………….

# មេរៀនព្រលឹងវិញ្ញាណៈ តើបន្ទុករបស់ខ្ញុំមានថ្ងៃបញ្ចប់ទេ?

**ណារីៈ** ចាស មេរៀនជីវិតយើងនៅថ្ងៃនេះនឹងនិយាយពី តើបន្ទុករបស់ខ្ញុំមានថ្ងៃបញ្ចប់ទេ។ ចាស បងប្អូនស្រ្តី តើអ្នកធ្លាប់មានអារម្មណ៍ថា ព្រះមិនអាចលឺអ្វីដែលនៅក្នុងចិត្តអ្នកដែរឬទេ? ហើយថា ជីវិតរបស់អ្នកជួបប្រទះតែការលំបាករហូត ធ្វើអោយអ្នកពិបាករស់នៅសំរាប់ថ្ងៃស្អែកបន្តទៀត? តើនៅពេលខ្លះអ្នកមានអារម្មណ៍ថា ដូចជាល្វើយ ហើយចុះចាញ់អ្វីៗដែលកើតឡើងនៅក្នុងជីវិតរបស់អ្នកដែរអត់?

**បូផាៈ** ចាស ពិតមែនហើយបងប្អូនស្រ្តី ខ្ញុំក៏ធ្លាប់មានអារម្មណ៍បែបនេះច្រើនដងដែរ ពិសេសនៅពេលដែលមានការអាក្រក់ជាច្រើនបានកើតឡើងចំពោះខ្ញុំ ដែលធ្វើអោយខ្ញុំគិតថា តើព្រះមានដែលយកព្រះទ័យទុកដាក់ចំពោះខ្ញុំដែរអត់? ហើយសំនួរនេះ ខ្ញុំជឿថា ពិតជាមានបងប្អូនខ្លះក៏ធ្លាប់សួរសំនួរនេះទៅកាន់ខ្លួនឯងដែរ មែនទេ?

**ណារីៈ** ចាស ពិតមែនហើយបង ខ្ញុំក៏ចង់សួរទៅកាន់បងប្អូនស្រ្តីយើងដែរថា នៅពេលដែលអ្នកកំពុងតយុទ្ធជាមួយអារម្មណ៍បែបនេះ ហើយធ្វើអោយជីវិតរបស់អ្នកមានបញ្ហា ហើយអ្នកមិនមានដំណោះស្រាយអ្វីទេ តើពេលនោះ អ្នកមានមិត្តណាម្នាក់មកអង្គុយស្តាប់ និងផ្តល់ជាយោបល់ដល់អ្នកដែរអត់? ឬមួយក៏គេទុកអ្នកចោលតែម្នាក់ឯង?

**បូផា:** ចាស បងប្អូនស្ត្រី មានបងស្រីម្នាក់ ដែលគាត់ធ្លាប់សួរសំនួរទាំងអស់នេះ តែក្រោយមកទើបគាត់ដឹងថា ព្រះទ្រង់ ស្មោះត្រង់ ហើយគាត់អាចទុកចិត្តទ្រង់ សំរាប់ថ្ងៃអនាគតរបស់គាត់ផងដែរ។ បងស្រីម្នាក់នោះ គាត់បានសំរេចចិត្តជឿលើព្រះបន្ទូលសន្យារបស់ព្រះ ទោះបីជាគាត់ស្ថិតនៅក្នុងស្ថានភាពលំបាកវេទនាអស់ជាច្រើនឆ្នាំ ដែលមើលទៅ ពិបាកពណ៌នាយ៉ាងណាក៏ដោយ។ គាត់ខ្សោយមែនទែន គាត់មិនអាចឈរនឹងបានទេ គឺគាត់ត្រូវលូនពីកន្លែងមួយទៅកន្លែងមួយទៀត ដើម្បីធ្វើការងារផ្ទះ។ សូម្បីតែគាត់មុជទឹក និងចំអិនអាហារដល់ក្រុមគ្រួសាររបស់គាត់ ក៏គាត់មានការពិបាកខ្លាំងដែរ។

**ណារី:** ចាស មានថ្ងៃមួយ គាត់មកពីផ្សារទិញម្ហូបវិញ គាត់ល្វើយ ហើយអស់កម្លាំងមែនទែនក្នុងការរៀបចំធ្វើម្ហូប។ គ្រូពេទ្យជាច្រើនបានពិនិត្យមើលអាការះជំងឺរបស់គាត់ តែគ្រូពេទ្យមិនដឹងថា គាត់មានជំងឺអ្វីច្បាស់លាស់ទេ។ គាត់បានចំណាយលុយជាច្រើន ដើម្បីរកវិធីព្យាបាលជំងឺដ៏ចំឡែករបស់គាត់។ គាត់បានអធិស្ឋានថ្វាយការនេះទៅកាន់ព្រះ តែគ្មានអ្វីប្រសើរឡើយ គឺគាត់នៅតែឈឺដដែរ។ មិត្តភក្តិគាត់បានបោះបង់ចោលគាត់ ដោយសារពួកគេមិនអាចចូលរួមទុក្ខលំបាកជាមួយគាត់បាន។ មានមិត្តភក្តិខ្លះបានផ្តល់ជាយោបល់ខ្លះៗដល់គាត់ តែមិនអាចជួយគាត់បានទេ។ ពេលខ្លះគ្រួសាររបស់គាត់ផ្ទាល់ធុញទ្រាន់នឹងជំងឺរបស់គាត់ និងមិនចង់ជួយគាត់បន្តទៀត។ ពេលខ្លះគាត់ឈឺធ្ងន់ ហើយញ៉ាំមិនបាន តែគ្រួសារគាត់បែរជាគិតថា គាត់ខ្ជិលច្រអូស ហើយធ្វើពុតទៅវិញ។ ភាពអស់កម្លាំង ល្វើយនេះ បានយាយីសុខភាពគាត់អស់

ជាច្រើនឆ្នាំ ហើយកាន់តែធ្វើអោយគាត់បាក់ទឹកចិត្តថែមទៀតនោះ គឺសូម្បីតែក្រុមគ្រួសាររបស់គាត់ ក៏មិនជឿគាត់ដែរ។ គាត់មានអារម្មណ៍ឯកោ និងទុក្ខព្រួយមែនទែន ហើយពេលខ្លះគាត់ក៏មានអារម្មណ៍ខឹងខ្លួនឯង។ គាត់បានអំពាវនាវទៅកាន់ព្រះទាំងអស់សង្ឃឹម។

**បូផា:** គាត់ចាប់ផ្តើមសួរព្រះថា ហេតុអ្វី ហេតុអ្វី??? តើនេះជាគំរោងការណ៍របស់ទ្រង់សំរាប់ខ្ញុំឬ? តើការនេះនឹងទៅជាយ៉ាងណា? គាត់ចាប់ផ្តើមមានអារម្មណ៍ថា គាត់ដាច់ចេញឆ្ងាយពីព្រះ គាត់មានសំនួរជាច្រើនសួរដល់ព្រះថា តើទ្រង់មានឃើញសណ្ឋានលំបាកវេទនារបស់ទូលបង្គំនៅពេលនេះទេ? តើទ្រង់មានខ្វល់ចំពោះទូលបង្គំអត់? ក្រោយមក បងស្រីម្នាក់នោះបាននឹកឃើញពីរឿងមួយនៅក្នុងព្រះគម្ពីរ ពីបុរសម្នាក់ឈ្មោះលោកយ៉ូប។ គាត់មានជំងឺសុះពេញរាងកាយរបស់គាត់ ហើយមិត្តគាត់បានសើចចំអកដាក់គាត់ នៅពេលគាត់ធ្វើអ្វីមិនកើត ហើយពួកគេទុកអោយគាត់នៅកំសត់តែម្នាក់ឯង។ សូម្បីតែប្រពន្ធគាត់ក៏ប្រើពាក្យសំដីមិនល្អចំពោះគាត់ដែរ។ លោកយ៉ូបបាត់បង់ផ្ទះសម្បែងដ៏ធំស្កឹមស្កៃ ដីស្រែចំការ កូនចៅ និងអ្នកបំរើរបស់គាត់ទាំងអស់។ ប៉ុន្តែលោកយ៉ូបជាអ្នកជឿដល់ព្រះយេស៊ូ។ គាត់ដឹងថា ព្រះអង្គស្រលាញ់គាត់ទោះបីគាត់កំពុងតែស្ថិតក្នុងស្ថានភាពឈឺចាប់វេទនា ខ្សោយ អស់កម្លាំង និងមានជំងឺរុំរ៉ៃយ៉ាងណាក៏ដោយ។ លោកយ៉ូបបាននិយាយទៅកាន់មិត្តរបស់គាត់ថា " ទោះបីទ្រង់សំលាប់ខ្ញុំក៏ដោយ គង់តែខ្ញុំទុកចិត្តដល់ទ្រង់ដែរ ប៉ុន្តែខ្ញុំនឹងចេះតែជជែកពីសេចក្តីសុចរិតនៃផ្លូវខ្ញុំ

នៅចំពោះទ្រង់ ឬ ព្រះអង្គនឹងប្រហារខ្ញុំ ខ្ញុំលែងមានសង្ឃឹមអ្វីទៀតហើយ ប៉ុន្តែខ្ញុំនឹងការពារខ្លួននៅចំពោះព្រះភ័ក្រ្តព្រះអង្គ។ (យ៉ូប១៣:១៥) ″។

**ណារី:** បន្ទាប់ពីគិតដល់រឿងលោកយ៉ូប បងស្រីម្នាក់នោះក៏បាននិយាយទៅកាន់ព្រះថា ‶ ព្រះយេស៊ូអើយ! ទូលបង្គំស្រលាញ់ព្រះអង្គ ហើយទុកចិត្តព្រះអង្គជានិច្ច។ សូមទ្រង់ប្រទានចិត្តដែលបរិសុទ្ធ ហើយអោយទូលបង្គំនៅតែសុចរិតនៅចំពោះទ្រង់″។ បងប្អូនស្រ្តី បងស្រីម្នាក់នោះ ដូចជាលោកយ៉ូបអញ្ចឹងដែរ គាត់ចាប់ផ្តើមទុកចិត្តព្រះ ហើយនៅជិតព្រះអង្គកាន់តែស្និតស្នាលជាងមុន ក្នុងពេលដែលគាត់កំពុងតែអស់កម្លាំង និងមានជំងឺប្រចាំកាយ។ គាត់បានជឿថា ទោះបីជាមានហេតុការណ៍អ្វីកើតឡើងចំពោះគាត់ក៏ដោយ គឺមានតែព្រះដែលជាអ្នកត្រួតត្រាលើជីវិតរបស់គាត់ ហើយគាត់អាចទុកចិត្តលើទ្រង់បាន។

**បូផា:** ចាស បងប្អូនស្រ្តី ជាមួយគ្នាផងដែរ ខ្ញុំក៏បាននឹកឃើញខគម្ពីរមួយ ដែលនៅក្នុងព្រះគម្ពីរទុតិយកថា ៣១:៦ បានចែងថា ‶ ចូរមានកម្លាំង និងចិត្តក្លាហានឡើង! កុំភ័យខ្លាច ឬ តក់ស្លុតនៅចំពោះមុខពួកគេអោយសោះ ដ្បិតព្រះអម្ចាស់ផ្ទាល់ ជាព្រះរបស់អ្នកនឹងយាងទៅជាមួយអ្នក។ ព្រះអង្គមិនបោះបង់ចោលអ្នកដាច់ខាត។″ ចាស ណារី ខគម្ពីរនេះពិតជាលើកទឹកចិត្តមែនទែន ហើយពិសេសអាចជួយបងច្រើននៅពេលដែលបងភ័យខ្លាចនឹងការអាក្រក់ណាមួយដែលនឹងត្រូវកើតឡើងចំពោះបង។

**ណារី:** ចាស ពិតមែនហើយបង ដូចជាបងស្រីម្នាក់ដែលយើងបានជំរាបជូនខាងលើអញ្ចឹង បន្ទាប់ពីគាត់នឹកឃើញពីគំរូរបស់លោកយ៉ូបហើយ រឿងនោះបានជួយលើកទឹកចិត្តគាត់មែនទែន ហើយគាត់កាន់តែមានជំនឿមាំទៅលើព្រះ ថែមទាំងជឿលើព្រះបន្ទូលសន្យារបស់ទ្រង់ថា ទ្រង់នឹងគង់ជាមួយនឹងគាត់រហូតតទៅ ទោះបីជាជីវិតគាត់ត្រូវបានបញ្ចប់នៅលើផែនដីនេះហើយក៏ដោយ។ គាត់ចាប់ផ្តើមសរសេរខគម្ពីរចងចាំ ដែលជាព្រះបន្ទូលសន្យារបស់ព្រះចំពោះជីវិតគាត់ ហើយទន្ទេញរាល់ថ្ងៃនូវរាល់ខគម្ពីរនោះ។ ព្រះអង្គបាននិយាយមកកាន់ចិត្តគាត់តាមរយៈខគម្ពីរ ហើយបានផ្តល់ក្តីសង្ឃឹម ការសំរាក និងភាពសុខសាន្តទៅក្នុងចិត្តគាត់ទៀតផង។

**បូផា:** គាត់បានអានព្រះគម្ពីរ និងគិតពិចារណាពីព្រះបន្ទូលទ្រង់ ពិសេសនៅពេលដែលគាត់មានទុក្ខព្រួយ ហើយមានអារម្មណ៍ឯកោ និងភ័យខ្លាច គាត់បែរទៅព្រះ ហើយទុកចិត្តលើព្រះអង្គ ដែលទ្រង់មានគ្រប់ទាំងអំណាចព្រះចេស្តា។ គាត់បានអានព្រះបន្ទូលរបស់ព្រះអង្គនៅក្នុងព្រះគម្ពីរទំនុកតម្កើង ១២១: ២ - ៤ ដែលបានប្រាប់ថា " គឺមានតែព្រះអម្ចាស់ដែលបានបង្កើតផ្ទៃមេឃ និងផែនដីប៉ុណ្ណោះ ដែលនឹងយាងមកជួយខ្ញុំ។ ព្រះអង្គមិនបណ្តោយអោយជើងរបស់អ្នកជំពប់ដួល ព្រះអង្គនឹងថែរក្សាការពារអ្នក ដោយឥតធ្វេសប្រហែស។ ព្រះអង្គដែលថែរក្សាការពារជនជាតិអ៊ីស្រាអែល ទ្រង់នឹងមិនងោកងុយ មិនផ្ទំលក់សោះឡើយ។" នៅត្រង់ខនេះ ធ្វើអោយគាត់មានទំនុកចិត្ត និងជួយកំសាន្តចិត្តដែលទន់ខ្សោយរបស់គាត់ទៀតផង។

**ណារី:** គាត់ក៏នៅតែបន្តអានព្រះគម្ពីរអេសាយ ៤០:២៨-៣១ ថា "**តើអ្នកមិនធ្លាប់លឺទេឬថា ព្រះអម្ចាស់ជាព្រះដែលគង់នៅអស់កល្បជានិច្ច បានបង្កើតផែនដីទាំងមូល? ព្រះអង្គមិនចេះនឿយហត់ មិនចេះអស់កម្លាំង រីឯព្រះតំរិះរបស់ព្រះអង្គ ក៏គ្មាននរណាអាចស្ទង់បានដែរ។ ព្រះអង្គប្រទានកម្លាំងពលំ ដល់អ្នកនឿយហត់ និងខ្សោះល្វើយ។ ក្មេងជំទង់ៗតែងនឿយហត់ និងអស់កម្លាំង ហើយមនុស្សពេញកម្លាំងក៏តែងភ្លាត់ដួលដែរ។ រីឯអ្នកជឿ សង្ឃឹមលើព្រះអម្ចាស់តែងតែមានកម្លាំងថ្មីជានិច្ច ប្រៀបបាននឹងសត្វឥន្ទ្រីហោះហើរ គេស្ទុះរត់ទៅមុខ ដោយមិនចេះហត់ ហើយដើរដោយមិនចេះអស់កម្លាំង។**" ក្រោយពេលដែលគាត់អានគម្ពីរហើយ គាត់បាននិយាយទៅកាន់ព្រះអង្គថា "ព្រះអង្គអើយ សូមទតមើលពីជីវិតទូលបង្គំ។ ទូលបង្គំសូមអំពាវនាវដល់ព្រះអង្គទាំងល្វើយ ហើយគ្មានកម្លាំងសោះ តើទ្រង់នឹងចំរើនកម្លាំងដល់ទូលបង្គំទេ? ទ្រង់សន្យាថា ទ្រង់អាចធ្វើបាន ដូច្នេះទូលបង្គំនឹងចាំព្រះបន្ទូលសន្យានេះទុក ដ្បិតទូលបង្គំជឿលើព្រះបន្ទូលសន្យារបស់ទ្រង់។ សូមជួយអោយទូលបង្គំអាចឈរនៅក្នុងសេចក្តីពិត សូមជួយបំពេញនូវព្រះបន្ទូលសន្យារបស់ទ្រង់ដល់ទូលបង្គំរាល់ថ្ងៃ។ ហើយនៅក្នុងដំណើរជីវិតរបស់ទូលបង្គំបន្តទៀត សូមអោយទូលបង្គំដឹងថាព្រះអង្គយកព្រះទ័យទុកដាក់ចំពោះទូលបង្គំ ហើយស្រលាញ់ទូលបង្គំ។"

**បូផា:** ចាស បងប្អូនស្ត្រី មិនតែប៉ុណ្ណោះ បងស្រីនោះ គាត់បានទទួលការលើកទឹកចិត្តទៀតនៅក្នុងព្រះគម្ពីរ ភីលីព ៤:៦-៧ ដែលបានប្រាប់ថា " **សូមកុំខ្វល់ខ្វាយនឹងអ្វីឡើយ ផ្ទុយទៅវិញ ក្នុង**

**គ្រប់កាលៈទេសៈទាំងអស់ ត្រូវទូលព្រះជាម្ចាស់អោយជ្រាបពីសំណូមពររបស់បងប្អូន ដោយអធិស្ឋាន និងទូលបង្វរ ទាំងអរព្រះគុណព្រះអង្គផង។ ធ្វើដូច្នេះ សេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់ដែលហួសពីការស្មានរបស់មនុស្ស នឹងស្ថិតជាប់ក្នុងចិត្តគំនិតបងប្អូនដែលរួមក្នុងអង្គព្រះគ្រិស្តយេស៊ូមិនខាន។”** ពេលនោះគាត់ក៏បានអធិស្ឋានអរព្រះគុណព្រះអង្គសំរាប់ព្រះពរទាំងប៉ុន្មាន ដែលទ្រង់បានប្រទានអោយគាត់។ គាត់បានអរព្រះគុណសំរាប់គ្រប់អ្វីៗទាំងអស់ដែលគាត់មាន ដូចជាខ្យល់ដកដង្ហើយ ទឹក អាហារ ព្រមទាំងក្រុមគ្រួសាររបស់គាត់។ គាត់អរព្រះគុណព្រះអង្គសំរាប់ការនេះ ព្រោះគាត់ដឹងថា របស់ទាំងអស់នោះជាអំណោយដែលបានមកពីព្រះជាម្ចាស់។

**ណារី:** ចាស បងបូផា ខ្ញុំយល់ស្របតាមគំនិតរបស់បងស្រីម្នាក់នេះ ហើយខ្ញុំគិតថា បទពិសោធន៍ជីវិតរបស់គាត់ជាមួយនឹងព្រះ គឺជាគំរូមួយល្អមែនទែនសំរាប់ខ្ញុំផ្ទាល់។ ចាស បងប្អូនស្រ្តី ខ្ញុំមិនដឹងថា បងប្អូនគិតដូចជាខ្ញុំអត់ទេ តែខ្ញុំក៏ចង់សួរដល់បងប្អូនដែរថា តើអ្នករត់រកព្រះអង្គ នៅពេលដែលអ្នកមានបញ្ហានៅក្នុងជីវិត ដូចជាបងស្រីដែលយើងខ្ញុំលើកមកនិយាយនេះទេ? តើអ្នកស្គាល់ព្រះអង្គ ហើយស្និតស្នាលជាមួយទ្រង់ ដូចជាមិត្តយ៉ាងជិតស្និតរបស់អ្នកដែរហើយឬនៅ? បើអ្នកស្គាល់ទ្រង់ និងមានភាពស្និតស្នាលជាមួយទ្រង់ដូចជាមិត្តអ្នកអាចនិយាយ និងជួបជាមួយទ្រង់រាល់ថ្ងៃ។

**បូផា:** បងប្អូនស្រ្តី តើអ្នកធុញទ្រាន់ក្នុងការរស់នៅដោយសារកម្លាំងរបស់ខ្លួនអត់? ព្រះអង្គបានរៀបចំផ្លូវមួយសំរាប់អ្នក ដើម្បីអោយអ្នកអាចនៅជិតព្រះអង្គ នៅពេលដែលជីវិតអ្នកមានបន្ទុកធ្ងន់ហួសកម្លាំង ហើយចេះតែខ្សោយទៅៗ។ ចាស ណារី និយាយត្រង់កន្លែងនេះ សូម្បីតែបងក៏ធ្លាប់ជួបប្រទះការនេះនៅក្នុងជីវិតដែរ តែបងដឹងថា ព្រះអង្គសន្យាថានឹងឆ្លើយតបដល់បង គឺទ្រង់បានប្តូរការភ័យខ្លាចដែលបងមានទៅជាការទុកចិត្តវិញ។ ទ្រង់លឺគ្រប់ពាក្យអធិស្ឋានរបស់បង ហើយទ្រង់ក៏ទតឃើញភាពឈឺចាប់របស់បងដែរ។

**ណារី:** ចាស បង ខ្ញុំជឿថា ព្រះទ្រង់នឹងសប្បាយចិត្ត នៅពេលយើងសរសើរតំកើងដល់ទ្រង់ ហើយទ្រង់នឹងផ្គត់ផ្គង់រាល់ទាំងសេចក្តីត្រូវការរបស់យើងជាមិនខាន។ ម្យ៉ាងវិញទៀត ព្រះអង្គអាចជួយអោយយើងមានកម្លាំងឡើងវិញ នៅពេលដែលយើងខ្សោយ ហើយអស់កម្លាំង។ ព្រះអង្គបានប្តូរគំនិតដែលខ្ញុំធ្លាប់គិតសង្ស័យជាមួយទ្រង់ អោយទៅជាឈប់សង្ស័យវិញ ព្រោះខ្ញុំដឹងថា ព្រះអង្គស្រលាញ់ខ្ញុំ ហើយចង់អោយខ្ញុំចូលទៅជិតព្រះអង្គ ហើយប្រាប់ទ្រង់ គ្រប់ទាំងភាពទន់ខ្សោយដែលខ្ញុំមានថែមទៀតផង។

**បូផា:** ចាស បងប្អូនស្រ្តី តើអ្នកនឹងចូលជិតទ្រង់ ហើយសូមអោយទ្រង់ជួយអ្នក ពេលដែលអ្នកល្វើយ ហើយអស់កម្លាំងដែរអត់? បើបងប្អូនចង់ សូមបានអធិស្ឋានជាមួយខ្ញុំ " ព្រះវរបិតា កូនអរព្រះគុណព្រះអង្គសំរាប់សេចក្តីស្រលាញ់ ការស្តាប់រាល់ការអធិស្ឋានរបស់កូន។ អរព្រះគុណដែលព្រះយេស៊ូបាននាំសន្តិភាពដល់ពួកកូន។ កូនទុកចិត្តព្រះអង្គក្នុងការដែលទ្រង់ជួយ

កូនដែលជាមនុស្សទន់ខ្សោយ អោយបានក្លាយជាស្ត្រីម្នាក់ដែលស្វែងរកព្រះអង្គជាទីមួយនៅក្នុងជីវិត។ អរព្រះគុណសំរាប់ព្រះបន្ទូលសន្យាដែលទ្រង់បង្រៀនកូនអោយរស់នៅក្នុងសេចក្តីពិតរបស់ទ្រង់។ អរព្រះគុណព្រះអង្គដែលទ្រង់មិនបានចាក់ចោលកូន ហើយក៏មិនបោះបង់កូនដែរ។ សូមអោយកូនដឹងថា ព្រះអង្គយកព្រះទ័យទុកដាក់ចំពោះកូន ហើយស្រលាញ់កូន នោះកូនមិនខ្វល់ខ្វាយអ្វីទៀតឡើយ ព្រោះព្រះអង្គជាព្រះលើអ្វីៗទាំងអស់។ កូនអរព្រះគុណទ្រង់ និងសូមអធិស្ឋានថ្វាយរាល់អ្វីទាំងអស់ដែលកូនមាន នៅក្នុងព្រះហស្តដ៏មានគ្រប់ទាំងអំណាចព្រះចេស្តា ព្រះអម្ចាស់ ព្រះយេស៊ូគ្រីស្ទ អាម៉ែន!!

## កំណាប់មរតក

**ណារី:** ចាស បងប្អូនស្ត្រី នៅក្នុងសប្តាហ៍នេះ យើងប្លែកពីធម្មតាបន្តិច គឺយើងនឹងលើកយកខគម្ពីរខ្លះៗមកអានជូនដែលខគម្ពីរនិយាយពីការសំរាកក្នុងព្រះគ្រីស្ទ។ ដូច្នេះសូមបានចូលរួមជាមួយយើងខ្ញុំដូចតទៅ។

**បុផ្ផា:** ចាស បងប្អូនស្ត្រី នៅក្នុងព្រះគម្ពីរទំនុកតម្កើង ៦២:១-២ បានប្រាប់ថា " មានតែនៅក្បែរព្រះជាម្ចាស់ទេ ដែលចិត្តខ្ញុំបានស្ងប់ ព្រោះព្រះអង្គសង្គ្រោះខ្ញុំ។ ព្រះអង្គតែមួយគត់ជាថ្មដា ជាព្រះសង្គ្រោះខ្ញុំ ព្រះអង្គជាកំពែងដ៏រឹងមាំ ដូច្នេះ ខ្ញុំនឹងមិនត្រូវបរាជ័យឡើយ។

**ណារី:** ចាស ហើយនៅក្នុងព្រះគម្ពីរម៉ាថាយ ១១:២៨-២៩ បានប្រាប់ថា " អស់អ្នកដែលនឿយហាត់ និងមានបន្ទុកធ្ងន់អើយ! ចូរមករកខ្ញុំ ខ្ញុំនឹងអោយអ្នករាល់គ្នាបានសំរាក។ ចូរយកនឹមរបស់ខ្ញុំ ដាក់លើអ្នករាល់គ្នា ហើយរៀនពីខ្ញុំទៅ អ្នករាល់គ្នាមុខជាបានស្ងប់ចិត្តមិនខាន ដ្បិតខ្ញុំស្លូត និងមានចិត្តសុភាព។"

**ភ្លេង**……………………………………….

**ណារី:** ចាស បងប្អូនស្ត្រី កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹមបានដល់ពេលវេលា ដែលត្រូវគោរពលាដល់បងប្អូនស្ត្រីហើយ។ ចាស យើងទាំងពីរនាក់សង្ឃឹមថា ពីកម្មវិធីយើងនៅថ្ងៃនេះ នឹងបានលើកទឹកចិត្តដល់បងប្អូនទាំងអស់គ្នា ហើយក៏សង្ឃឹមថា បងប្អូននឹងយកអ្វីដែលយើងខ្ញុំបានជំរាបជូន នៅថ្ងៃនេះទៅពិចារណាផងដែរ។ ប្រសិនបើបងប្អូនមានចំងល់ បងប្អូនអាចទំនាក់ទំនងមកកាន់តាមរយៈទូរសព្ទលេខ ០៩២ ៦០ ៦០ ៥១ និង ០៨៨ ៥៥៦ ៩៩ ៥៥។

**បូផា:** កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម ផលិតដោយអង្គការត្រេសន៍វើលកម្ពុជា។ កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម សូមលំអោនកាយជំរាបលា ប្រិយមិត្តអ្នកស្តាប់ត្រឹមប៉ុណ្ណេះសិន។ សន្យាថានឹងវិលមកជួបគ្នាម្តងទៀត នៅសប្តាហ៍ក្រោយ តាមពេលវេលាដដែល ម៉ោងដដែល។ សូមព្រះប្រទានពរ!!